# រឿងក្ដីទំនួលខុសត្រូវ និងសិទ្ធិឪពុក-ម្ដាយ៖ អ្វីដែលត្រូវធ្វើជាមួយនឹងទម្រង់បែបបទតុលាការទាំងនេះ

នេះគឺជារបៀបមួយចំនួនក្នុងការបំពេញទម្រង់បែបបទទាំងឡាយ៖

- ត្រូវប្រើឈ្មោះពេញតាមច្បាប់ជានិច្ច មិនត្រូវប្រើឈ្មោះហៅក្រៅនោះទេ។
- វាយកុំព្យូទ័រ ឬ បោះពុម្ពឲ្យដោយមានរបៀប។ ទម្រង់ដែលអាចបំពេញបាន គឺមាននៅលើគេហទំព័រ៖ http://courts.maine.gov/fees_forms/forms។
- អ្នកនឹងដាក់ទម្រង់នីមួយៗទៅតុលាការ។ មុនពេលដាក់ទៅតុលាការ សូមថតចម្លងទម្រង់ដែលបានបំពេញរួចយ៉ាងតិចពីរច្បាប់–មួយសម្រាប់ខ្លួនឯង និងមួយទៀតសម្រាប់ភាគីម្ខាងទៀត។ អ្នកនឹងត្រូវរកកន្លែងដើម្បីថតចម្លង (ដូចជានៅបណ្ណាល័យ)។ ក្រឡាបញ្ជីតុលាការមិនអាចថតចម្លងឯកសារឲ្យអ្នកនោះទេ។
- ប្រសិនបើកូនណាមួយដែលពាក់ព័ន្ធនឹងរឿងក្ដីនេះ ទទួលបាន (ឬបានទទួល) AFDC, TANF ឬ Medicaid សូមថតចម្លងបន្ថែមនូវលិខិតស្នាមរបស់តុលាការ ហើយផ្ញើឯកសារទាំងនោះតាមសំបុត្រទៅក្រសួងសេវាមនុស្សជាតិ។ អាសយដ្ឋានមាននៅលើទម្រង់បែបបទបណ្ដឹង។ អ្នកក៏គួរតែធ្វើរបៀបនេះ ប្រសិនបើអ្នកបានស្នើសុំឲ្យ DHS បើកអាហារកិច្ចកូនឲ្យអ្នក។

<u>**ជំហានទីមួយ៖ បំពេញទម្រង់បែបបទ**</u>

## បណ្ដឹងសម្រាប់ការកំណត់បិតុភាព, ទំនួលខុសត្រូវ និងសិទ្ធិឪពុក-ម្ដាយ, អាហារកិច្ចសម្រាប់កូន

ផ្នែកដែលនៅខាងលើបំផុតនៃទម្រង់បែបបទហៅថា "ចំណងជើង"។ សូមបំពេញទីតាំងរបស់តុលាការមណ្ឌល (District Court) (ឧទាហរណ៍៖ "Bangor")។ ក្រឡាបញ្ជីនឹងបំពេញលេខសំណុំរឿង (Docket Number) ពេលក្រោយ។ អ្នកជាដើមចោទ (Plaintiff) ហើយភាគីម្ខាងទៀតជាចុងចោទ (Defendant)។ សូមបំពេញឈ្មោះពេញតាមច្បាប់ ក្នុងចន្លោះពីមុខពាក្យ "ដើមចោទ"។ សូមសរសេរឈ្មោះពេញរបស់ភាគីម្ខាងទៀតនៅចន្លោះដែលនៅពីមុខពាក្យ "ចុងចោទ"។ សូមបំពេញចន្លោះផ្សេងទៀតនៅក្នុងទម្រង់បែបបទ។ នៅជិតចុងបញ្ចប់ មានពាក្យថា "សំណើរបស់ដើមចោទ" សូមគូសប្រអប់ទាំងឡាយណាដែលត្រូវនឹងអ្នក។ បើសិនអ្នកមិនប្រាកដទេនោះ សូមគូសប្រអប់។ អ្នកអាចដកសំណើនោះនៅពេលក្រោយ។) អ្នកត្រូវតែចុះហត្ថលេខាលើទម្រង់បែបបទនេះនៅចំពោះមុខសាការីសាធារណៈ។ អ្នកអាចរកសាការីនៅឯធនាគារ ការិយាល័យសេវាច្បាប់ តាមរយៈការិយាល័យក្រុងរបស់អ្នក ឬនៅការិយាល័យក្រឡាបញ្ជី។

## លិខិតបញ្ជាក់អះអាងអាហារកិច្ចកូន

សូមបំពេញ "ចំណងជើង" ដូចដែលអ្នកបានបំពេញនៅលើទម្រង់ពាក្យបណ្ដឹង។ សូមបំពេញផ្នែកដែលនៅសល់នៃទម្រង់នេះ តាមការយល់ដឹងប្រសើរបំផុតរបស់អ្នក។ សូមកត់សម្គាល់ថា អ្នកសរសេរបញ្ជាក់ពីចំណូលដែលរកបានកាលពីឆ្នាំមុន និងចំណូលដែលរំពឹងនឹងរកបាននៅឆ្នាំនេះ ដាច់ដោយឡែកនៅក្រោម #1។ សូមកត់សម្គាល់ផងដែរថា អ្នកសរសេរបញ្ជាក់ពីចំណូលផ្សេងទៀតនៅក្រោម #2 និងចំណូលមិនមែនជាលុយ នៅក្រោម #3។ អ្នកអាចនឹងពិនិត្យមើលកំណត់ត្រារបស់អ្នក ប្រសិនបើអ្នកមាន ដើម្បីទទួលបានព័ត៌មានហិរញ្ញវត្ថុ។ អ្នកត្រូវតែចុះហត្ថលេខាលើទម្រង់បែបបទនេះនៅចំពោះមុខសាការីសាធារណៈ។ បន្ទាប់ពីចុងចោទទទួលបណ្ដឹងរបស់អ្នក តុលាការនឹងស្នើឲ្យគាត់បំពេញទម្រង់បែបបទហិរញ្ញវត្ថុដូចគ្នា ហើយផ្ញើមួយច្បាប់ជូនអ្នក។

## ដីកាកោះស្ដីពីវិវាទគ្រួសារ និងអធិបញ្ញាបឋម

អ្នកត្រូវតែប្រើទម្រង់បែបបទសំណៅដើមដែលអ្នកបានទទួលពីក្រឡាបញ្ជី។ ដីកានោះមានហត្ថលេខា និងត្រាដើមរបស់ក្រឡាបញ្ជី។ អ្នកមិន

អាចប្រើសំណៅចម្លង ឬទម្រង់នេះដែលទាញយកពីអ៊ីនធឺណិតទេ។

សូមបំពេញ "ចំណងជើង" ដូចដែលបានបំពេញនៅលើពាក្យបណ្តឹង។ សូមបំពេញឈ្មោះ និងអាសយដ្ឋានតុលាការ។ សូមចុះកាលបរិច្ឆេទ និងហត្ថលេខានៅលើទម្រង់បែបបទ។ សូមទុកចន្លោះនៅទំព័រទីពីរឲ្យនៅទំនេរ។

**ទម្រង់បែបបទលាតត្រដាង លេខសន្តិសុខសង្គម**

អ្នកត្រូវបានតម្រូវដោយច្បាប់រដ្ឋ និងសហព័ន្ធ ក្នុងការផ្តល់លេខសន្តិសុខសង្គមរបស់អ្នក ព្រមទាំងលេខសន្តិសុខសង្គមរបស់កូនៗ។ ព័ត៌មាននេះត្រូវបានប្រមូលលើទម្រង់បែបបទលាតត្រដាងលេខសន្តិសុខសង្គម (Social Security Number Disclosure) ដែលដាក់ក្នុងស្រោមសំបុត្ររក្សាការសម្ងាត់នៅក្នុងឯកសាររបស់អ្នក។ ទម្រង់បែបបទនេះ ត្រូវបានដាក់បញ្ចូលក្នុងកញ្ចប់របស់អ្នក។

**<u>ជំហានទីពីរ៖ បញ្ជូនទម្រង់បែបបទ</u>**

ពេលនេះ អ្នកត្រូវតែផ្តល់សំណៅចម្លងនានាទៅឲ្យភាគីម្ខាងទៀត។ ការធ្វើដូច្នេះហៅថា "ការបញ្ជូន" លិខិតស្នាមរបស់តុលាការ។ វិធានតុលាការចែងថា អ្នកអាចផ្តល់លិខិតស្នាមតាមវិធីមួយក្នុងចំណោមវិធីចំនួនបី។ អ្នកអាចផ្ញើលិខិតស្នាមតាមប្រៃសណីយ៍ ដោយសុំឲ្យភាគីម្ខាងទៀតផ្តល់ការយល់ព្រមចំពោះ "ការផ្តល់ឯកសារ"។ អ្នកអាចផ្ញើក្រដាសស្នាមតាមលិខិតអនុសិដ្ឋ (certified mail)។ អ្នកអាចបង់ប្រាក់ឲ្យនគរបាល (sheriff) ម្នាក់ ដើម្បីប្រគល់ឯកសារច្បាប់ចម្លងឲ្យភាគីម្ខាងទៀត។

**ការផ្តល់ឯកសារតាមប្រៃសណីយ៍**

សូមផ្ញើតាមប្រៃសណីយ៍ ឬប្រគល់ដោយផ្ទាល់ដៃនូវលិខិតស្នាមទាំងនេះ ទៅឲ្យភាគីម្ខាងទៀត៖

- សំណៅចម្លងនៃពាក្យបណ្តឹង
- សំណៅចម្លងនៃដីកា និងអធិបញ្ញាបឋម
- សំណៅចម្លងនៃលិខិតបញ្ជាក់អះអាងអាហារកិច្ចកូន
- សំណៅចម្លងពីរច្បាប់នៃលិខិតបញ្ជាក់ការទទួលបានដីកា និងពាក្យបណ្តឹង (បន្ទាប់ពីអ្នកបានបំពេញ "ចំណងជើង" នៅលើសំណៅចម្លងទាំងពីររួច)
- ស្រោមសំបុត្រដែលមានបិតតែម និងអាសយដ្ឋានអ្នកផ្ញើរួចជាស្រេច

ទម្រង់បែបបទទទួលស្គាល់ការទទួលបាន (Acknowledgment of Receipt) ស្នើឲ្យភាគីម្ខាងទៀតចុះហត្ថលេខាលើវា ដោយបង្ហាញថាគាត់បានទទួលលិខិតស្នាមទាំងនោះ ហើយត្រូវបញ្ជូនទម្រង់បែបបទនេះមកឲ្យអ្នកវិញក្នុងរយៈពេល 20ថ្ងៃ។ ប្រសិនបើអ្នកទទួលបានលិខិតទទួលស្គាល់ដែលចុះហត្ថលេខារួច ក្នុងរយៈពេល 20ថ្ងៃ សូមបន្តទៅជំហានទី 3។ បើពុំដូច្នេះទេ អ្នកនឹងត្រូវបញ្ជូនលិខិតស្នាមតាមវិធីមួយផ្សេងទៀត។

**ការផ្តល់ឯកសារតាមលិខិតអនុសិដ្ឋ**

សូមយកលិខិតស្នាមទាំងនេះទៅកាន់ប៉ុស្តិ៍ប្រៃសណីយ៍ដោយដាក់ក្នុងស្រោមសំបុត្រ៖

- សំណៅចម្លងនៃពាក្យបណ្តឹង
- សំណៅចម្លងនៃដីកា និងអធិបញ្ញាបឋម
- សំណៅចម្លងនៃលិខិតបញ្ជាក់អះអាងអាហារកិច្ចកូន

សូមប្រាប់បុគ្គលិកប្រៃសណីយ៍ថា អ្នកចង់ផ្ញើលិខិតស្នាមតាមលិខិតអនុសិដ្ឋ។ ត្រូវប្រាកដថា អ្នកសុំ "បង្កាន់ដៃបញ្ជាក់ការទទួលបានសំបុត្រ (Return Receipt)" និង "សេវាបញ្ជូនតឹងរឹង (Restricted Delivery)"។ វិធីនេះត្រូវចំណាយច្រើនជាង ហើយពាក់ព័ន្ធនឹងជំហានពីរបីបន្ថែមទៀត។ ទម្រង់លិខិតអនុសិដ្ឋដែលតឹងរឹង គឺមាននៅប៉ុស្តិ៍ប្រៃសណីយ៍របស់អ្នក។ សូមដាក់ប័ណ្ណពណ៌បៃតងដែលអ្នកទទួលបានវិញពីប៉ុស្តិ៍ប្រៃសណីយ៍ ឲ្យទៅក្រឡាបញ្ជីតុលាការ ដើម្បីបញ្ជាក់ថា ភាគីម្ខាងទៀតបានទទួលលិខិតស្នាមរួចហើយ។

**ការប្រគល់ឯកសារតាមនគរបាល**

សូមផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍ ឬ នាំយកទៅការិយាល័យនគរបាលខោនធីរបស់អ្នកនូវ៖

- សំណៅចម្លងនៃពាក្យបណ្តឹង
- សំណៅដើមនៃដីកា និងអធិបញ្ញាបឋម និងសំណៅចម្លងមួយច្បាប់។
- សំណៅចម្លងនៃលិខិតបញ្ជាក់អះអាងអាហារកិច្ចកូន

នៅក្នុងលិខិត ឬ ការជួបផ្ទាល់ សូមស្នើសុំការិយាល័យនគរបាល ឲ្យបញ្ជូនលិខិតស្នាមបន្តទៅឲ្យភាគីម្ខាងទៀត។ សូមផ្តល់អាសយដ្ឋានផ្ទះ និង/ឬកន្លែងធ្វើការរបស់ភាគីម្ខាងទៀត។ ភ្នាក់ងារ ដែល "បញ្ជូន" លិខិតស្នាមទាំងឡាយ នឹងបំពេញទំព័រទីពីរនៃដីកា ហើយប្រគល់សំណៅដើមទៅឲ្យអ្នកវិញ។ នគរបាលនឹងគិតថ្លៃសេវានេះ (ប្រហែលជា $20-$40)។

### ជំហានទីបី ៖ ដាក់ទម្រង់បែបបទ

បំពេញទំព័រសង្ខេបអំពីវិវាទគ្រួសារ (Family Matter Summary Sheet) ដែលក្នុងនោះមានសេចក្តីណែនាំស្រាប់។ ក្រឡាបញ្ជីតុលាការនឹងមិនទទួលយកលិខិតស្នាមរបស់អ្នកដោយគ្មានទម្រង់បែបបទនេះឡើយ។

ក្នុងរយៈពេល 20ថ្ងៃ បន្ទាប់ពីបញ្ជូនឯកសារឲ្យភាគីម្ខាងទៀត សូមប្រគល់ដោយផ្ទាល់ ឬ ផ្ញើតាមប្រៃសណីយ៍ទៅឲ្យក្រឡាបញ្ជីតុលាការនូវសំណៅដើមនៃទម្រង់បែបបទទាំងនេះ៖

- ☐ **ទំព័រសង្ខេប**
- ☐ **ពាក្យបណ្តឹង**
- ☐ **ទម្រង់បែបបទលាតត្រដាងលេខសន្តិសុខសង្គម (SSN)**
- ☐ **លិខិតបញ្ជាក់អះអាងអាហារកិច្ចកូន**
- ☐ **ដីកា** (ត្រូវការចាំបាច់ មិនថាប្រគល់តាមវិធីណានោះទេ និងគួរតែដាក់ដោយមានហត្ថលេខារបស់ភ្នាក់ងារ **ប្រសិនបើអ្នកប្រើសេវារបស់នគរបាល**)
- ☐ **លិខិតទទួលស្គាល់ការទទួលបាន** (ប្រសិនបើអ្នកបានប្រើសេវាផ្ញើតាមប៉ុស្តិ៍ប្រៃសណីយ៍)
- ☐ **ប័ណ្ណពណ៌បៃតង** (ប្រសិនបើអ្នកប្រើសេវាលិខិតអនុសិដ្ឋ)

តុលាការគិតថ្លៃសេវាសម្រាប់ការដាក់លិខិតស្នាមរបស់អ្នក។ បន្ទាប់មកអ្នកអាចនឹងត្រូវបានគិតថ្លៃសេវាសម្រុះសម្រួល (បែងចែករវាងគូភាគី)។ អ្នកគួរតែទាក់ទងក្រឡាបញ្ជីតុលាការដើម្បីឲ្យដឹងពីចំនួនជាក់លាក់។ ប្រសិនបើអ្នកមិនមានលទ្ធភាពបង់ប្រាក់ប្រដាប់ក្តី អ្នកអាចសុំពីក្រឡាបញ្ជីនូវពាក្យសុំដំណើរការនីតិវិធីដោយពុំចាំបាច់បង់ប្រាក់ (Application to Proceed Without Payment of Fees) និងលិខិតបញ្ជាក់អះអាងមួយ។ បំពេញទម្រង់បែបបទទាំងនេះ ហើយចុះហត្ថលេខានៅចំពោះមុខសាការីសាធារណៈ។ បន្ទាប់មកដាក់ទម្រង់ទាំងនោះនៅក្រឡាបញ្ជី ព្រមជាមួយនឹងលិខិតស្នាមផ្សេងៗទៀតរបស់អ្នក។ ចៅក្រមម្នាក់នឹងពិនិត្យព័ត៌មានហិរញ្ញវត្ថុរបស់អ្នក ហើយសម្រេចថាតើអ្នកត្រូវនឹងលក្ខខណ្ឌដើម្បីទទួលការលើកលែងការបង់ប្រាក់ដែរឬទេ។ ប្រសិនបើការលើកលែងត្រូវបានបដិសេធ អ្នកត្រូវតែបង់ថ្លៃដាក់ឯកសារក្នុងរយៈពេល 7ថ្ងៃ។ បើសិនអ្នកទទួលបានការលើកលែង អ្នកនឹងមិនចាំបាច់បង់ប្រាក់មួយចំនួន ឬទាំងអស់នោះទេ។

### ជំហានទីបួន៖ ការប្រជុំអំពីការគ្រប់គ្រងរឿងក្តី

អ្នក និងភាគីម្ខាងទៀត ត្រូវតែទៅការប្រជុំអំពីការគ្រប់គ្រងរឿងក្តីនៅតុលាការ។ ក្នុងរយៈពេលពីរសប្តាហ៍ បន្ទាប់ពីអ្នកបំពេញគ្រប់ជំហានខាងលើ តុលាការនឹងជូនដំណឹងដល់អ្នកអំពីកាលបរិច្ឆេទ និងម៉ោងនៃការប្រជុំនោះ។ សូមអានលិខិតស្នាមទាំងអស់ ដែលអ្នកទទួលបានពីតុលាការ រួមទាំងឯកសារដែលមានចំណងជើង៖ ព័ត៌មានសំខាន់ទាក់ទងនឹងការប្រជុំអំពីការគ្រប់គ្រងរឿងក្តី។

ប្រសិនបើអ្នក និងភាគីម្ខាងទៀត ព្រមព្រៀងគ្នាតាមការរៀបចំបណ្តោះអាសន្នសម្រាប់កូនរបស់អ្នក (ដូចជាកន្លែងដែលពួកគេស្នាក់នៅ ការជួបសួរសុខទុក្ខជាមួយឪពុក-ម្តាយម្ខាងទៀត និងរបៀបដែលពួកគេនឹងត្រូវបានឧបត្ថម្ភ) អ្នកអាចនឹងបំពេញ ហើយដាក់ទម្រង់មួយ ហៅថាលិខិតបញ្ជាក់ជំនួសការប្រជុំអំពីការគ្រប់គ្រងរឿងក្តី (Certificate in Lieu of Case Management Conference)។ អ្នកអាចទទួលបានទម្រង់នេះពីក្រឡាបញ្ជីតុលាការ។ អ្នក និងភាគីម្ខាងទៀត ត្រូវតែចុះហត្ថលេខាទាំងពីរអ្នកលើលិខិតបញ្ជាក់នោះ។ អ្នកអាចនឹងមិនចាំបាច់ទៅការប្រជុំអំពីការគ្រប់គ្រងរឿងក្តីឡើយ ប្រសិនបើអ្នកដាក់លិខិតបញ្ជាក់នេះ មុនកាលបរិច្ឆេទនៃការប្រជុំនោះ។

តុលាការនឹងផ្ញើលិខិតជូនដំណឹងមួយដល់អ្នកតាមសំបុត្រ ប្រសិនបើអ្នកមិនចាំបាច់ទៅការប្រជុំនោះទេ។

ប្រសិនបើអ្នក និងភាគីម្ខាងទៀត ចង់ទៅធ្វើការសម្រុះសម្រួលជាមុន អ្នកអាចស្នើសុំតុលាការនូវ "ការពន្យាពេល" នៃការប្រជុំអំពីការគ្រប់គ្រងរឿងក្តីបានរហូតដល់ 90ថ្ងៃ។ ក្រឡាបញ្ជីតុលាការអាចផ្តល់ទម្រង់មួយ ហៅថា "ការពន្យាពេលនៃការប្រជុំអំពីការគ្រប់គ្រងរឿងក្តី (Deferral of Case Management Conference)" ដែលអ្នក **និង**ភាគីម្ខាងទៀត ឬមេធាវី ត្រូវតែចុះហត្ថលេខា។ សូមឲ្យប្រាកដថាបានដាក់ថ្លៃសេវាសម្រុះសម្រួល នៅពេលអ្នកដាក់ទម្រង់បែបបទពន្យាពេលទៅក្រឡាបញ្ជីតុលាការ។ ក្រឡាបញ្ជីតុលាការនឹងផ្តល់កាលបរិច្ឆេទសម្រាប់ការសម្រុះសម្រួលដល់អ្នក ហើយការប្រជុំអំពីការគ្រប់គ្រងរឿងក្តី នឹងធ្វើឡើង បន្ទាប់ពីការសម្រុះសម្រួលបានបញ្ចប់។

## ប្រភពជំនួយនានា

**វីដេអូ៖** តុលាការភាគច្រើនមានវីដេអូ ដែលពន្យល់ពីដំណើរការតុលាការ ព្រមទាំងសិទ្ធិ និងទំនួលខុសត្រូវរបស់អ្នក។ ប្រសិនបើអ្នកចង់ទស្សនាវីដេអូនេះ សូមទាក់ទងក្រឡាបញ្ជីតុលាការ។

**ការសម្រុះសម្រួល៖** អ្នកសម្រុះសម្រួលអាចនឹងជួយអ្នក និងភាគីម្ខាងទៀត ឲ្យឈានដល់ការព្រមព្រៀងគ្នាលើបញ្ហានានាទាក់ទងនឹងរឿងក្តីរបស់អ្នក។ តុលាការមានវីដេអូមួយដែលពន្យល់ថាអ្វីទៅដែលថាការសម្រុះសម្រួល។ ការសម្រុះសម្រួលអាចត្រូវបានរៀបចំឡើងតាមរយៈតុលាការ ឬ អ្នកសម្រុះសម្រួលឯកជន។

**ការអប់រំឪពុក-ម្តាយ៖** កម្មវិធីអប់រំឪពុក-ម្តាយ ដែលត្រូវបានរៀបចំបង្កើតឡើងជាពិសេសសម្រាប់ឪពុកម្តាយដែលកំពុងលែងលះ ឬនៅបែកគ្នា អាចនឹងជួយអ្នកផ្តោតលើតម្រូវការនានារបស់កូនរបស់អ្នក។ តុលាការអាចនឹងបង្គាប់ឲ្យអ្នកចូលរួមការប្រជុំមួយក្នុងចំណោមការប្រជុំរយៈពេលបួនម៉ោងទាំងនេះ។

**តាមអាហារកិច្ចកូន៖** តាមច្បាប់ គោលការណ៍ណែនាំទាំងនេះ ត្រូវបានចេញដោយ DHHS និងត្រូវបានប្រើដើម្បីជួយកំណត់កាតព្វកិច្ចអាហារកិច្ចកូន ទៅតាមប្រាក់ចំណូល។ តារាងនេះអាចរកបាននៅលើប្រព័ន្ធអ៊ីនធើណេតតាមរយៈ៖ http://courts.maine.gov/fees_forms/forms/index.shtml ឬពីការិយាល័យរបស់ក្រឡាបញ្ជីតុលាការមណ្ឌលណាមួយ។

សម្រាប់ព័ត៌មានបន្ថែមអំពីប្រភពទាំងនេះ សូមទៅជួបក្រឡាបញ្ជីតុលាការ ឬ ចូលកាន់គេហទំព័រផ្នែកយុត្តិធម៌របស់រដ្ឋ Maine ដែលមានអាសយដ្ឋាន៖ http://courts.maine.gov ។

## ទំព័រសេចក្ដីសង្ខេបអំពីវិវាទគ្រួសារ

M.R. Civ. P. 5(h)

**សម្គាល់៖** ទម្រង់បែបបទនេះគឺសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ។ សូមបំពេញជាភាសាអង់គ្លេសនៅក្នុងទម្រង់បែបបទភាសាអង់គ្លេស។ ប្រសិនបើអ្នកត្រូវការជំនួយ សូមទៅកាន់ការិយាល័យក្រឡាបញ្ជី ហើយគេនឹងហៅទូរសព្ទទៅសេវាបកប្រែ។

ទម្រង់នេះប្រើប្រាស់សម្រាប់បញ្ចូលព័ត៌មានជាមូលដ្ឋានពាក់ព័ន្ធនឹងរឿងក្ដី និងភាគីពាក់ព័ន្ធ ទៅក្នុងកំណត់ត្រារបស់តុលាការ។ អ្នកត្រូវបំពេញទម្រង់នេះឱ្យបានពេញលេញជាមួយនឹងក្រឡាបញ្ជី នៅពេលដែលអ្នកដាក់ពាក្យប្ដឹង ឬពាក្យសុំ។ អ្នកមិនតម្រូវឱ្យប្រគល់សំណៅចម្លងនៃទម្រង់នេះទៅឱ្យភាគីម្ខាងទៀតនោះទេ។

| |
|---|
| **ទីតាំងតុលាការ** (កន្លែងដែលអ្នកដាក់ពាក្យប្ដឹង) |

**ប្រភេទនៃបណ្ដឹង៖** (ជ្រើសរើសប្រអប់ណាមួយ)

| | |
|---|---|
| ☐ លែងលះ - ពាក់ព័ន្ធនឹងអចលនវត្ថុ | ☐ លែងលះ - មិនមានអចលនវត្ថុ |
| ☐ អំណាចមេបា និងការទទួលខុសត្រូវ (ឪពុកម្ដាយរបស់កូនរស់នៅជាអនីតិសង្វាស) ☐ ស្វែងរកបិតុភាព (ស្វែងរកឪពុកបង្កើតរបស់កូន) | |
| ☐ ការដាក់ឱ្យនៅបែកគ្នាតាមផ្លូវតុលាការ | ☐ សាលក្រមបរទេស |
| ☐ វិវាទគ្រួសារផ្សេងទៀត | |

**ប្រភេទនៃការដាក់ពាក្យ៖** (ជ្រើសរើសប្រអប់ណាមួយ)

| |
|---|
| ☐ នីតិវិធីដើម |
| ការស្នើសុំក្រោយមានសាលក្រម៖ ☐ ដើម្បីកែប្រែ ☐ ដើម្បីអនុវត្ត ☐ សម្រាប់ការប្រមាថតុលាការ<br>លេខសំណុំរឿងដើមគឺ៖ |

**ព័ត៌មានរបស់ដើមបណ្ដឹង៖** (បុគ្គលដែលដាក់ពាក្យប្ដឹង ឬប្រសិនបើក្រោយមានសាលក្រម ឈ្មោះរបស់បុគ្គលដែលធ្លាប់ជាដើមបណ្ដឹងនៅក្នុងសំណុំរឿងដើម)

| នាម៖ នាម | កណ្ដាល | គោត្តនាម | ឈ្មោះដើម (មុនពេលរៀបការ) |
|---|---|---|---|

| អាសយដ្ឋានផ្ញើសំបុត្រ | ក្រុង | រដ្ឋ | ប្រៃសណីយ៍ |
|---|---|---|---|
| អាសយដ្ឋានរាងកាយ | ក្រុង | រដ្ឋ | ប្រៃសណីយ៍ |

| ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខផ្សព្វផ្សាយ SS ដែលតម្រូវនៅក្នុងទម្រង់ដាច់ដោយឡែក |
|---|---|---|

| | | |
|---|---|---|
| លេខទូរស័ព្ទនៅផ្ទះ៖ | | លេខទូរស័ព្ទកន្លែងធ្វើការ៖ |
| ឈ្មោះមេធាវី៖ | | អត្តលេខនៅគណៈមេធាវី៖ |

**<u>ព័ត៌មានរបស់ចុងចម្លើយ៖</u>** (បុគ្គលដែលត្រូវបានប្តឹង ឬប្រសិនបើក្រោយមានសាលក្រម ឈ្មោះបុគ្គលដែលធ្លាប់ជាចុងចម្លើយនៅក្នុងសំណុំរឿងដើម។

| នាម៖ នាម | កណ្តាល | គោត្តនាម | ឈ្មោះដើម (មុនពេលរៀបការ) |
|---|---|---|---|

| | | | |
|---|---|---|---|
| អាសយដ្ឋានផ្ញើសំបុត្រ | ក្រុង | រដ្ឋ | ប្រៃសណីយ៍ |
| អាសយដ្ឋានរាងកាយ | ក្រុង | រដ្ឋ | ប្រៃសណីយ៍ |

| | | |
|---|---|---|
| ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខផ្សព្វផ្សាយ SS ដែលតម្រូវនៅក្នុងទម្រង់ដាច់ដោយឡែក |

| | |
|---|---|
| លេខទូរស័ព្ទនៅផ្ទះ៖ | លេខទូរស័ព្ទកន្លែងធ្វើការ៖ |
| ឈ្មោះមេធាវី៖ | អត្តលេខនៅគណៈមេធាវី៖ |

| នាមនិងគោត្តនាមនៃ**កូនជាអនីតិជន** (នៃភាគីខាងលើ)៖ | ថ្ងៃខែឆ្នាំកំណើត៖ | ភេទ៖ | |
|---|---|---|---|
| | | | លេខផ្សព្វផ្សាយ SS ដែលតម្រូវ |
| | | | លេខផ្សព្វផ្សាយ SS ដែលតម្រូវ |
| | | | លេខផ្សព្វផ្សាយ SS ដែលតម្រូវ |
| | | | លេខផ្សព្វផ្សាយ SS ដែលតម្រូវ |
| | | | លេខផ្សព្វផ្សាយ SS ដែលតម្រូវ |
| | | | លេខផ្សព្វផ្សាយ SS ដែលតម្រូវ |

កាលបរិច្ឆេទ៖ ______________________

______________________

ហត្ថលេខារបស់ភាគី (មេធាវីរបស់ភាគី)

រដ្ឋ MAINE

| | |
|---|---|
| **តុលាការកំពូល** | **តុលាការមណ្ឌល** |
| ______________________, ss. | ទីតាំង______________________ |
| សំណុំរឿងលេខ ____________________ | សំណុំរឿងលេខ ____________________ |

**សម្គាល់៖** ទម្រង់បែបបទនេះគឺសម្រាប់ជាឯកសារយោងប៉ុណ្ណោះ។ សូមបំពេញជាភាសាអង់គ្លេសនៅក្នុងទម្រង់បែបបទភាសាអង់គ្លេស។ ប្រសិនបើអ្នកត្រូវការជំនួយ សូមទៅកាន់ការិយាល័យក្រលាបញ្ជី ហើយគេនឹងហៅទូរសព្ទទៅសេវាបកប្រែ។

រដ្ឋ MAINE/______________________

ដើមចោទ

v.

______________________________

ចុងចោទ

**ទម្រង់បែបបទលាតត្រដាងព័ត៌មានសម្ងាត់នៃលេខសន្តិសុខសង្គម**

លេខគណនីសន្តិសុខសង្គមរបស់ខ្ញុំគឺ ____________ - ______ - _____________.

កាលបរិច្ឆេទ៖ ___________________ ______________________________

ដើមចោទ/ចុងចោទ

<u>សម្រាប់តែសំណុំរឿងបញ្ហាគ្រួសារប៉ុណ្ណោះ (ការលែងលះ សិទ្ធិ និងទំនួលខុសត្រូវរបស់ឪពុកម្ដាយ)</u>

1. ប្រសិនបើសំណុំរឿងនេះជាសំណុំរឿងបញ្ហាគ្រួសារ កូនដែលពាក់ព័ន្ធក៏ត្រូវលាតត្រដាងលេខសន្តិសុខសង្គមរបស់ពួកគេផងដែរ៖

| ឈ្មោះកូន | លេខសន្តិសុខសង្គម |
|---|---|
| | |
| | |
| | |
| | |
| | |

2. ☐ សំណុំរឿងរក្សាការពារ (Protective Custody) បច្ចុប្បន្នស្ថិតក្នុងការរង់ចាំការសម្រេចឬដំណោះស្រាយ, តុលាការ/សំណុំរឿងលេខ៖___________________________________

ទម្រង់បែបបទនេះគឺជាការសម្ងាត់ និងមិនត្រូវលាតត្រដាងឡើយ លើកលែងតែមានសេចក្ដីបង្គាប់ពីតុលាការ។

CV/CR/FM/PC-200, Rev. 06/14 Khmer

រដ្ឋ MAINE

តុលាការមណ្ឌល

ទីតាំង ______________________________

សំណុំរឿងលេខ__________________________

**ចំណាំ៖** ទម្រង់បែបបទនេះគឺសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ។ សូមបំពេញជាភាសាអង់គ្លេស នៅក្នុងទម្រង់បែបបទជាភាសាអង់គ្លេស។ ប្រសិនបើអ្នកត្រូវការជំនួយ សូមទៅកាន់ការិយាល័យក្រឡាបញ្ជី ហើយគេនឹងហៅទូរសព្ទទៅសេវាបកប្រែ។

______________________________ដើមបណ្តឹង

v.

______________________________ចុងចម្លើយ

**បណ្តឹងស្នើសុំ**
**កំណត់បិតុភាព, ទំនួលខុសត្រូវ និងសិទ្ធិឪពុក-ម្តាយ,**
**អាហារកិច្ចរបស់កូន**

M.R. Civ. P. 10(a), 19-A M.R.S. §§ 1553 & 1652

1. ដើមបណ្តឹង និងចុងចម្លើយ ដែលមិនទាន់រៀបការនឹងគ្នា គឺជាឪពុកម្តាយរបស់កូនដូចខាងក្រោម៖

| *ឈ្មោះ* | *ថ្ងៃខែឆ្នាំកំណើត* | *អាសយដ្ឋានបច្ចុប្បន្ន* |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |

2. ដើមបណ្តឹងស្នាក់នៅ *(ទីក្រុង)* __________________, *(ខោនធី)* ______________________, *(រដ្ឋ)*___________ ។

**ប្រសិនបើភាគីណាមួយមានបំណងរក្សាអាសយដ្ឋានរបស់ខ្លួនជាការសម្ងាត់ ភាគីនោះត្រូវបំពេញលិខិតបញ្ជាក់អាសយដ្ឋានការសម្ងាត់ (ទម្រង់ FM-057)។ ទម្រង់បែបបទនេះអាចរកបាននៅការិយាល័យក្រឡាបញ្ជី ឬនៅ៖**

**http://courts.maine.gov/fees_forms/forms។**

3. ចុងចម្លើយស្នាក់នៅ *(ទីក្រុង)* _____________, *(ខោនធី)* ______________________, *(រដ្ឋ)*___________។

4. A. បញ្ជីខាងក្រោមនេះ គឺជាកន្លែង និងបុគ្គលដែលកូនបានរស់នៅជាមួយក្នុងរយៈពេល **5 ឆ្នាំចុងក្រោយ៖**

| ឈ្មោះបុគ្គល និងអាសយដ្ឋានបច្ចុប្បន្នដែលកូនបានរស់នៅជាមួយ | កាលបរិច្ឆេទដែលកូនបានរស់នៅជាមួយបុគ្គលនោះ | ក្រុង និងរដ្ឋដែលកូនបានរស់នៅជាមួយបុគ្គលនោះ |
|---|---|---|
| | | |
| | | |

B. ដើមបណ្ដឹងមិនមានជាប់ពាក់ព័ន្ធ ហើយក៏គ្មានព័ត៌មានអំពីសំណុំរឿងតុលាការនៅរដ្ឋណាមួយ ពាក់ព័ន្ធនឹងសិទ្ធិគ្រប់គ្រងថែរក្សាកូន លើកលែងតែមានករណីដូចខាងក្រោម៖

☐ ការការពារពីការរំលោភបំពាន

☐ ផ្សេងៗ (ពណ៌នាអំពីករណីផ្សេងទៀត) ______________________________

C. ក្រៅពីភាគីទាំងពីរ គ្មានបុគ្គលណាម្នាក់មានសិទ្ធិគ្រប់គ្រងថែរក្សាកូន ឬទាមទារសិទ្ធិគ្រប់គ្រងថែរក្សា ឬទាមទារសិទ្ធិជួបជាមួយកូន លើកលែងតែមានករណីដូចខាងក្រោម៖ ______________________________

5. **(ចូរគូសធីកក្នុងប្រអប់ដែលពាក់ព័ន្ធ)**

☐ កូនមិនធ្លាប់ទទួលអត្ថប្រយោជន៍ជំនួយសាធារណៈទេ។

**ឬ**

☐ កូនបានទទួល កំពុងទទួល ឬនឹងទទួលបានអត្ថប្រយោជន៍ជំនួយសាធារណៈ។

**និង**

☐ ដើមបណ្ដឹងបានផ្ញើសេចក្ដីចម្លងនៃបណ្ដឹងនេះទៅកាន់ក្រសួងសុខាភិបាល និងសេវាមនុស្សកិច្ចទៅតាមអាសយដ្ឋានដូចខាងក្រោម៖ *ផ្នែកជំនួយកុមារ អ្នកគ្រប់គ្រងការិយាល័យកណ្ដាល វិមានរដ្ឋទី 11 Augusta, ME 04333-0011*។ (សេចក្ដីចម្លងត្រូវផ្ញើ នៅពេលដែលកូនបានទទួល កំពុងទទួល ឬនឹងទទួលបានអត្ថប្រយោជន៍ជំនួយសាធារណៈ។)

☐ ក្រសួងសុខាភិបាល និងសេវាមនុស្សកិច្ច **បាន**ចេញសេចក្ដីបង្គាប់ស្ដីពីអាហារកិច្ចរបស់កុមារ។ *(ប្រសិនបើទទួលបាននូវការចេញនូវសេចក្ដីបង្គាប់ សំណៅចម្លងនៃសេចក្ដីបង្គាប់នោះត្រូវតែភ្ជាប់មកជាមួយនឹងបណ្ដឹងនេះ)។*

☐ ក្រសួងសុខាភិបាល និងសេវាមនុស្សកិច្ច **បាន**ចុះកិច្ចសន្យាដើម្បីបង្កើត ពិនិត្យឡើងវិញ កែប្រែ ឬអនុវត្តសេចក្ដីបង្គាប់ស្ដីពីអាហារកិច្ចរបស់កុមារ។

**ដើមបណ្ដឹងស្នើសុំឱ្យផ្ដល់ជូននូវការលែងលះ ហើយតុលាការត្រូវ៖ (ចូរគូសធីកក្នុងប្រអប់ដែលពាក់ព័ន្ធ)**

☐ បង្គាប់ឱ្យធ្វើតេស្តពិនិត្យមើលប្រភេទឈាម ឬជាលិកា ដោយអនុលោមតាម 19-A M.R.S. § 1558។

☐ សម្រេចថាគូភាគីគឺជាឪពុកម្ដាយរបស់កូនដែលបានរៀបរាប់នៅក្នុងបណ្ដឹងនេះ។

☐ កំណត់អំពីអំណាចមេបា និងការកាទទួលខុសត្រូវចំពោះកូនជាអនីតិជន ដោយអនុលោមតាម 19-A M.R.S. § 1653 រួមបញ្ចូលទាំងអាហារកិច្ចរបស់កូនផងដែរ។

☐ កំណត់ចំនួនទឹកប្រាក់ដែលត្រូវផ្តល់ជាអាហារកិច្ចកូនពីពេលមុនមក ហើយបង្គាប់ឱ្យបង់អាហារកិច្ចពីពេលនោះមក។

☐ បែងចែកសំណងលើការចំណាយពេលសម្រាលកូន ព្រមទាំងថ្លៃចំណាយផ្នែកវេជ្ជសាស្រ្តសម្រាប់កូន។

☐ បង់ថ្លៃសេវាមេធាវីសមស្របទៅឱ្យមេធាវីរបស់ដើមបណ្តឹង។

កាលបរិច្ឆេទ៖ ____________________ ____________________

ហត្ថលេខាដើមបណ្តឹង

មេធាវីដើមបណ្តឹង៖ ____________________ ដើមបណ្តឹង៖ ____________________

អាសយដ្ឋាន៖____________________ អាសយដ្ឋាន៖____________________

____________________ ____________________

ទូរស័ព្ទ៖ ____________________ ទូរស័ព្ទ៖ ____________________

រដ្ឋ MAINE

ខោនធី ____________________

បានបង្ហាញខ្លួនដោយផ្ទាល់ ដើមបណ្តឹងខាងលើឈ្មោះ ____________________ ហើយបានសច្ចាថារាល់សេចក្តីថ្លែងទាំងអស់គឺជាការពិត។

ចំពោះមុខយើង

កាលបរិច្ឆេទ៖ ____________________ ____________________

(មេធាវី) (សារការីសាធារណៈ) (ក្រឡាបញ្ជីរង)

រដ្ឋ Maine

តុលាការមណ្ឌល
ទីតាំង ______________________
សំណុំរឿងលេខ________________

ដើមបណ្តឹង៖ ________________________

V.

**ចំណាំ៖** ទម្រង់បែបបទនេះគឺសម្រាប់ជាឯកសារយោងតែប៉ុណ្ណោះ។ សូមបំពេញជាភាសាអង់គ្លេសនៅក្នុងទម្រង់បែបបទជាភាសាអង់គ្លេស។ ប្រសិនបើអ្នកត្រូវការជំនួយ សូមទៅកាន់ការិយាល័យក្រឡាបញ្ជី ហើយ គេនឹងទាក់ទងទៅសេវាបកប្រែ។ទម្រង់បែបបទនេះក៏មាន[http://courts.maine.gov/fees_forms/forms](http://courts.maine.gov/fees_forms/forms) ផងដែរ។

ចុងចម្លើយ៖ ___________________________
អាសយដ្ឋាន___________________________
____________________________________

**ដីកាកោះហៅអំពីវិវាទគ្រួសារ**
**និង**
**អធិបញ្ញាបឋម**
19-A M.R.S. §§ 852 និង 903

ចំពោះចុងចម្លើយ៖
ដើមបណ្តឹងបានដាក់ពាក្យប្តឹងអ្នកដើម្បីទាមទារចំណុចណាមួយដូចជា៖ ការលែងលះ ការដាក់ឱ្យនៅបែកគ្នាតាមផ្លូវតុលាការ ការទាមទារអំណាចមេបានិងការទទួលខុសត្រូវ ការស្វែងរកបិតុភាព ឬអាហារកិច្ចរបស់កូន។ ប្រសិនបើអ្នកចង់ជំទាស់ទៅនឹងបណ្តឹងនេះ **អ្នកត្រូវផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរ ហើយប្រសិនបើមានកូនជាអនីតិជន ត្រូវផ្តល់មកជាមួយនូវលិខិតបញ្ជាក់ស្តីពីអាហារកិច្ចរបស់កូនចំពោះដើមបណ្តឹង** ក្នុងរយៈពេល 20 ថ្ងៃ បន្ទាប់ពីទទួលបានដីកាកោះហៅនេះមក។ បណ្តឹង និងសេចក្តីបញ្ជាក់អំពីអាហារកិច្ចរបស់កូនដែលមានភ្ជាប់មកជាមួយនេះត្រូវប្រគល់ជូនអ្នក។ ដើម្បីផ្តល់សារណា និងសេចក្តីបញ្ជាក់របស់អ្នក អ្នកត្រូវផ្តល់ច្បាប់ចម្លងនៃឯកសារទាំងនោះដោយផ្ទាល់ ឬផ្ញើសំបុត្រទៅឱ្យមេធាវីរបស់ដើមបណ្តឹង ឬដើមបណ្តឹង ដែលមានឈ្មោះ និងអាសយដ្ឋាននៅខាងក្រោមទំព័រនេះ។ ក្នុងរយៈពេល 20 ថ្ងៃ អ្នកត្រូវដាក់សារណាច្បាប់ដើម និងសេចក្តីបញ្ជាក់ច្បាប់ដើមទៅតុលាការ ដោយផ្ញើសំបុត្រទៅ៖

ឈ្មោះ និងអាសយដ្ឋានតុលាការ៖

| |
|---|
| |

**អធិបញ្ញាបឋម**
**(សម្រាប់ការលែងលះ និងការដាក់ឱ្យនៅបែកគ្នាតាមផ្លូវតុលាការតែប៉ុណ្ណោះ)**

អនុលោមតាម 19-A M.R.S. §§ 852 និង 903 **បង្គាប់ឲ្យ**ដើមបណ្តឹង និងចុងចម្លើយមិនត្រូវ៖

(1) លក់ ផ្ទេរ បរិច្ចាគ ដាក់បញ្ចាំ លាក់បាំង ដាក់បន្ទុក ឬបំផ្លាញចោលទ្រព្យសម្បត្តិណាមួយដែលកម្មសិទ្ធិផ្ទាល់ខ្លួន ឬរួមគ្នារបស់គូភាគី លើកលែងតែវាត្រូវបានធ្វើឡើងដោយ (a) មានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីភាគីទាំងពីរ (b) ដើម្បីទិញវត្ថុចាំបាច់សម្រាប់ទ្រទ្រង់ជីវិត (c) នៅក្នុងការប្រព្រឹត្តិទៅជាធម្មតានៃអាជីវកម្មរបស់ភាគីណាមួយ ឬ (d) ដោយមានការព្រមព្រៀងពីតុលាការ។

(2) កំណត់សេរីភាពផ្ទាល់ខ្លួនរបស់ភាគីម្ខាងទៀត ឬកូនបង្កើត ឬកូនចិញ្ចឹមរបស់ភាគីណាមួយ ឬ

(3) ដកភាគីម្ខាងទៀត ឬកូនណាមួយនៃគូភាគីចេញពីការធានារ៉ាប់រងក្រោមគោលការណ៍ធានារ៉ាប់រងសុខភាពណាមួយ។

**ការក្រើនរំលឹក**

**នេះគឺជាដីកាបង្គាប់ជាផ្លូវការរបស់តុលាការ។ បើអ្នកមិនគោរពតាមដីកាបង្គាប់នេះទេ តុលាការនឹងសន្មត់ថាអ្នកប្រមាថតុលាការ។ ដីកាបង្គាប់នេះមានសុពលភាពទាល់តែករណីណាមួយ ដូចខាងក្រោម កើតឡើងមុន៖ (1) លុបចោល ឬកែប្រែ។ (2) ចេញដីកាចុងក្រោយចំពោះការលែងលះ ឬការដាក់ឱ្យនៅបែកគ្នាតាមផ្លូវតុលាការ។ ឬ (3) ច្រានចោលបណ្ដឹង។**

កាលបរិច្ឆេទ៖_______________________

ដីកាកោះហៅ (និងអធិបញ្ញា)នេះ ចេញដោយ៖

_______________________

ក្រឡាបញ្ជីនៃតុលាការមណ្ឌល

(មេធាវីរបស់ដើមបណ្ដឹង) (ដើមបណ្ដឹង)៖

ឈ្មោះ៖_______________________

អាសយដ្ឋាន៖_______________________

_______________________

ទូរស័ព្ទ៖ (______) _______________________

**ព័ត៌មានសំខាន់សម្រាប់ចុងចម្លើយ**

ប្រសិនបើអ្នកមិនផ្ដល់និងដាក់សារណាតបទៅនឹងបណ្ដឹង និង "សេចក្ដីបញ្ជាក់អំពីអាហារកិច្ចចំពោះកូន" ក្នុងករណីពាក់ព័ន្ធនឹងកូនជាអនីតិជន ឬប្រសិនបើអ្នកមិនមានវត្តមាននៅតុលាការ នៅពេលដែលអ្នកត្រូវបានជូនដំណឹងឱ្យមានវត្តមាន តុលាការអាចចេញសេចក្ដីសម្រេចទៅតាមការទាមទាររបស់ដើមបណ្ដឹង ទោះបីជាអវត្តមានរបស់អ្នកក៏ដោយ។

ប្រសិនបើអ្នកមិនចង់ផ្ដល់ និងដាក់សារណាតបទៅនឹងបណ្ដឹង ប៉ុន្តែអ្នកចង់ឱ្យតុលាការស្ដាប់អ្នកពាក់ព័ន្ធនឹងវិវាទអាហារកិច្ចចំពោះកូន អំណាចមេបា ការបែងចែកទ្រព្យអាពាហ៍ពិពាហ៍ អាហារកិច្ចចំពោះប្ដី/ប្រពន្ធ ថ្លៃសេវាមេធាវី អ្នកត្រូវបំពេញទម្រង់ "បង្ហាញវត្តមាន" និងសេចក្ដីថ្លែងសច្ចាអំពីអាហារកិច្ចចំពោះកូន ហើយដាក់នៅតុលាការ និងត្រូវចូលរួមក្នុងកិច្ចប្រជុំ និងសវនាការរបស់តុលាការ។ អ្នកត្រូវផ្ដល់ឱ្យដើមបណ្ដឹងនូវច្បាប់ចម្លងនៃសេចក្ដីថ្លែងសច្ចាពេញលេញ និងការចូលទៅបង្ហាញវត្តមាន។ ទម្រង់ "សេចក្ដីថ្លែងសច្ចាអំពីអាហារកិច្ចចំពោះកូន" និងទម្រង់ "បង្ហាញវត្តមាន" អាចស្វែងរកនៅការិយាល័យក្រឡាបញ្ជី។

ប្រសិនបើអ្នកជឿជាក់ថាអ្នកមានការការពារតទល់នឹងបណ្ដឹងរបស់ដើមបណ្ដឹង ឬការទាមទាររបស់អ្នកទល់នឹងដើមបណ្ដឹង អ្នកគួរតែជជែកជាមួយមេធាវី។ <u>ក្រឡាបញ្ជីមិនត្រូវបានអនុញ្ញាតឱ្យផ្ដល់យោបល់ឱ្យអ្នកទេ។</u>

**ការជូនដំណឹងទៅកាន់គូភាគី**

**នៅគ្រប់ករណីទាំងអស់ពាក់ព័ន្ធនឹងកូនជាអនីតិជន គូភាគីត្រូវចូលរួមកិច្ចជំនុំជម្រះស្ដីពីករណីសំណុំរឿងនៅតុលាការ។ ក្នុងរយៈពេលពីរសប្ដាហ៍បន្ទាប់ពីដើមបណ្ដឹងដាក់ភស្តុតាងស្ដីពីការការប្រគល់ជូនដីកាកោះហៅ ពាក្យបណ្ដឹង និងសេចក្ដីបញ្ជាក់អំពីអាហារកិច្ចចំពោះកូន មកតុលាការ តុលាការនឹងជូនដំណឹងទៅអ្នកអំពីកាលបរិច្ឆេទ និងពេលវេលានៃកិច្ចជំនុំជម្រះនោះ។ ការជូនដំណឹងនឹងត្រូវផ្ញើតាមរយៈសំបុត្រធម្មតា។ អ្នកត្រូវជូនដំណឹងជាបន្ទាន់មកកាន់តុលាការអំពីអាសយដ្ឋានពិតប្រាកដរបស់អ្នក និងការផ្លាស់ប្ដូរអាសយដ្ឋានរបស់អ្នក។ ប្រសិនបើអ្នកមិនធ្វើដូចនោះទេ អ្នកនឹងមិនទទួលបានការជូនដំណឹងណាមួយពីតុលាការឡើយ រួមទាំងការជូនដំណឹងអំពីកិច្ចជំនុំជម្រះស្ដីពីករណីសំណុំរឿងផងដែរ។**

ការក្រើនរំលឹកសំខាន់៖ អ្នកមានសិទ្ធិចូលរួម និងស្តាប់គ្រប់ព្រឹត្តិការណ៍នានា(ការកាត់សេចក្តី សវនាការ កិច្ចជំនុំជម្រះ ការផ្សះផ្សា) នៅតុលាការ។ ប្រសិនបើអ្នកខកខានមិនមានវត្តមាននៅក្នុងព្រឹត្តិការណ៍នានារបស់តុលាការដោយគ្មានមូលហេតុត្រឹមត្រូវនោះទេ ចំណាត់ការអាចធ្វើឡើងចំពោះសំណុំរឿងរបស់អ្នក បើទោះបីជាអ្នកមិនបានចូលរួមក៏ដោយ។ នេះមានន័យថាទោះជាអ្នកអវត្តមានក៏ដោយ ក៏តុលាការអាចចេញដីកាបង្គាប់បណ្តោះអាសន្ន ឬ បើកសវនាការចុងក្រោយ ហើយចេញដីកាបង្គាប់ចុងក្រោយ ឬសាលដីកាសម្រេចចុងក្រោយពាក់ព័ន្ធទៅនឹងចំណុចវិវាទណាមួយ ឬទាំងអស់នៅក្នុងសំណុំរឿងរបស់អ្នក រួមទាំងបិតុភាព អំណាចមេបានិងការទទួលខុសត្រូវចំពោះកូន (ការថែរក្សា ការស្នាក់នៅ ទំនាក់ទំនង ការសួរសុខទុក្ខជាដើម) អាហារកិច្ចចំពោះកូន អាហារកិច្ចចំពោះប្តី/ប្រពន្ធ ថ្លៃសេវាមេធាវី និងការបែងចែកទ្រព្យអាពាហ៍ពិពាហ៍ និងមិនមែនអាពាហ៍ពិពាហ៍ (បំណុល អចលនទ្រព្យ យានយន្ត ទ្រព្យសម្បត្តិផ្ទាល់ខ្លួន គណនីសោធននិវត្តន៍ ជាដើម)។ តុលាការក៏មានអំណាចក្នុងការច្រានចោលរាល់នីតិវិធីនៃបណ្តឹងដែលអ្នកបានដាក់ជូនផងដែរ ប្រសិនបើអ្នកមិនមកបង្ហាញខ្លួននោះទេ។ នេះគឺជាការទទួលខុសត្រូវរបស់អ្នកដើម្បីធានាថាតុលាការមានអាសយដ្ឋានត្រឹមត្រូវរបស់អ្នក។ ការផ្លាស់ប្តូរអាសយដ្ឋានត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងបញ្ជូនទៅការិយាល័យក្រឡាបញ្ជី ដោយផ្ទាល់ដៃ ឬតាមសេវាផ្ញើសំបុត្រធម្មតា។

**រដ្ឋ Maine**

រដ្ឋ ______________________________ ,ss.

ថ្ងៃ ______________________________ (កាលបរិច្ឆេទ), ខ្ញុំបានបំពេញចំណាត់ការបណ្តឹង ដីកាកោះហៅ និងអធិបញ្ញាបឋម និងសេចក្តីបញ្ជាក់អំពីអាហារកិច្ចចំពោះកូន ដោយបានបញ្ជូនច្បាប់ចម្លងនៃឯកសារទាំងនេះ ទៅតាមអាសយដ្ឋានដូចខាងក្រោម៖

______________________________________________________________________

☐ ទៅឱ្យចុងចម្លើយដែលមានឈ្មោះដូចបានរៀបរាប់ខាងលើ ដោយផ្ទាល់ដៃ។

☐ ទៅឱ្យ ______________________________ (ឈ្មោះ) ជាបុគ្គលដែលមានអាយុ និងឆន្ទានុសិទ្ធិគ្រប់គ្រាន់ ដែលរស់នៅផ្ទះរបស់ចុងចម្លើយ។

☐ ទៅឱ្យ ______________________________ (ឈ្មោះ) ជាអ្នកទទួលការអនុញ្ញាតឯកសារជូនចុងចម្លើយ។

☐ ដោយ (ពិពណ៌នាអំពីមធ្យោបាយបញ្ជូនឯកសារផ្សេងទៀត)៖ ______________________________

______________________________________________________________________

**ការចំណាយសម្រាប់ការបញ្ជូន៖**

សេវាកម្ម៖ $______________________

ធ្វើដំណើរ $______________________

ថ្លៃបញ្ជូនសំបុត្រ $______________________

ផ្សេងៗ $______________

**សរុប $**______________________

______________________________

ហត្ថលេខារបស់បុគ្គលដែលបញ្ជូនឯកសារ

______________________________

ឋាន:

ឬ ការបញ្ជូនឯកសារត្រូវធ្វើឡើងដោយភ្ជាប់មកជាមួយនូវជម្រើសណាមួយខាងក្រោម៖

☐ ទម្រង់បែបបទនៃការទទួលស្គាល់ដីកា (ភ្ជាប់មកជាមួយ)

☐ បណ្ណបៃតង បង្កាន់ដៃទទួល (ភ្ជាប់មកជាមួយ)

☐ សេវាបញ្ជូនឯកសារដទៃទៀត (ភ្ជាប់មកជាមួយ)

រដ្ឋ MAINE

**តុលាការកំពូល**

_______________________, ss.

សំណុំរឿងលេខ _______________________

_______________________

**តុលាការមណ្ឌល**

ទីតាំង_______________________

សំណុំរឿងលេខ

**សម្គាល់៖** ទម្រង់បែបបទនេះគឺសម្រាប់ជាឯកសារយោងប៉ុណ្ណោះ។ សូមបំពេញជាភាសាអង់គ្លេសនៅក្នុងទម្រង់បែបបទភាសាអង់គ្លេស។ ប្រសិនបើអ្នកត្រូវការជំនួយ សូមទៅកាន់ការិយាល័យក្រលាបញ្ជី ហើយគេនឹងហៅទូរសព្ទទៅសេវាបកប្រែ។

_______________________ ដើមចោទ

v.

_______________________ ចុងចោទ

**ការទទួលស្គាល់ការទទួលបានដីកាកោះ និងពាក្យបណ្ដឹង ឬ សំណើសុំក្រោយចេញសាលក្រម**

M.R. Civ. P. 4(c)(1)

**សម្គាល់**

សូមចុះហត្ថលេខាបញ្ជាក់ការទទួលស្គាល់នៅខាងក្រោម រួចផ្ញើទម្រង់បែបបទនេះក្នុងស្រោមសំបុត្រដែលមានបិទតែម អាសយដ្ឋានអ្នកផ្ញើ ដែលត្រូវបានភ្ជាប់មកជាមួយនេះ ដើម្បីឲ្យអ្នកផ្ញើទទួលបានទម្រង់បែបបទនេះវិញក្នុងរយៈពេល 20 ថ្ងៃ បន្ទាប់ពីថ្ងៃដែលគេផ្ញើវាទៅកាន់អ្នក។ ប្រសិនបើអ្នកមិនធ្វើដូច្នេះទេ អ្នកអាចនឹងត្រូវបានតម្រូវដោយតុលាការឲ្យបង់ប្រាក់សម្រាប់ថ្លៃចំណាយលើការបញ្ជូនដីកាកោះ និងពាក្យបណ្ដឹង ឬ សំណើសុំក្រោយចេញសាលក្រមនេះឲ្យអ្នក។

**(សូមរក្សាសំណៅនៃទម្រង់បែបបទនេះ និងសំណៅនៃពាក្យបណ្ដឹង ឬ សំណើសុំមួយច្បាប់ ទុកជាឯកសាររបស់អ្នក។)**

---

**សេចក្ដីថ្លែងអះអាង**

ដោយចុះហត្ថលេខា ចុះកាលបរិច្ឆេទ និងបញ្ជូនទម្រង់បែបបទនេះត្រលប់ទៅវិញ ខ្ញុំសូមអះអាងថា ខ្ញុំបានទទួលដីកាកោះ និងពាក្យបណ្ដឹងមួយច្បាប់ ឬ សំណើសុំក្រោយចេញសាលក្រមមួយច្បាប់ និងសូមអះអាងថា៖

**ចំពោះគ្រប់រឿងក្ដីនៅតុលាការរដ្ឋប្បវេណី រួមទាំងការលែងលះ ការផ្ដាច់សង្វាសតាមច្បាប់ និង សិទ្ធិនិងទំនួលខុសត្រូវរបស់ឪពុកម្ដាយ** ខ្ញុំយល់ដឹងថា ប្រសិនបើខ្ញុំមិនផ្ដល់ចម្លើយតបចំពោះពាក្យបណ្ដឹង ឬ ដាក់បណ្ដឹងជំទាស់ចំពោះសំណើសុំនោះ ក្នុងរយៈពេលកំណត់ដោយលក្ខន្តិកៈ ឬ វិធានរបស់តុលាការ និងមិនបានបង្ហាញខ្លួននៅរាល់ការប្រជុំ និងសវនាការតុលាការ នោះសាលក្រមអាចនឹងត្រូវបានចេញប្រឆាំងនឹងខ្ញុំដោយកំបាំងមុខខ្ញុំ ហើយដើមបណ្ដឹង ឬភាគីដាក់សំណើអាចស្នើសុំឲ្យចេញសេចក្ដីបង្គាប់ផ្សេងៗទៀតប្រឆាំងនឹងខ្ញុំ។

**ចំពោះរឿងក្ដីលែងលះ ការផ្ដាច់សង្វាសតាមច្បាប់ និង សិទ្ធិនិងទំនួលខុសត្រូវរបស់ឪពុកម្ដាយ** ខ្ញុំយល់ដឹងថា ប្រសិនបើខ្ញុំមិនមានបំណងដាក់ពាក្យផ្ដល់ចម្លើយតបចំពោះពាក្យបណ្ដឹង ប៉ុន្តែខ្ញុំពិតជាចង់ប្រាប់ឲ្យគេដឹងអំពីបញ្ហានានានៃសិទ្ធិនិងទំនួលខុសត្រូវរបស់ឪពុកម្ដាយពាក់ព័ន្ធនឹងកូនរបស់ខ្ញុំ សោធនអាហារកិច្ច ប្រាក់ឧបត្ថម្ភ ថ្លៃប្រឹក្សា និងការបែងចែកទ្រព្យសម្បត្តិរួមប្ដី-ប្រពន្ធ និងទ្រព្យមិនជាប់ចំណងអាពាហ៍ពិពាហ៍ ខ្ញុំត្រូវតែដាក់ទម្រង់បែបបទចូលបង្ហាញខ្លួនដោយមានមេធាវីតំណាង (Entry of Appearance) និងបង្ហាញមុខនៅរាល់ការជំនុំជម្រះ និងសវនាការតុលាការទាំងអស់។ ខ្ញុំអាចនឹងដាក់

ពាក្យផ្តល់ចម្លើយ និងបណ្តឹងតប (ទម្រង់ FM/186/FM-187) ចំពោះពាក្យបណ្តឹងលែងលះ ឬ សិទ្ធិនិងទំនួលខុសត្រូវរបស់ឪពុកម្តាយ។ ប្រសិនបើខ្ញុំមានបំណងដាក់ពាក្យផ្តល់ចម្លើយ និងបណ្តឹងតប ខ្ញុំយល់ដឹងថា ខ្ញុំត្រូវដាក់ពាក្យផ្តល់ចម្លើយ និងបណ្តឹងតបក្នុងរយៈពេល 20 ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។ អ្នកអាចទទួលបានពាក្យផ្តល់ចម្លើយ និងបណ្តឹងតប នៅតុលាការមណ្ឌលណាមួយក៏បាន ឬ នៅគេហទំព័រ www.courts.state.me.us។

កាលបរិច្ឆេទ៖ ____________________

________________________________
ហត្ថលេខា

អាសយដ្ឋាន៖ ______________________
______________________

ទូរស័ព្ទ៖ (__________) ______________________

**សេចក្តីព្រមានជាមុនសំខាន់**

